**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**

**ប្រចាំអូស្ត្រាលី**

លេខ: 50/21 / REC/CBR

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលីនិងនូវែលហ្សេឡង់ សូមជម្រាបជូនបងប្អូននិស្សិត និងប្រជាពលរដ្ឋខ្មែរកំពុងរស់នៅក្នុងប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ថា ក្រសួងការបរទេសនូវែលហ្សេឡង់បានជូនដំណឹងស្តីពីការបើកព្រំដែនប្រទេសទាំងពីរ ឱ្យធ្វើដំណើរចេញ-ចូល ដោយពុំចាំបាច់ធ្វើចត្តាឡីស័ក (quarantine-free) ចាប់ពីម៉ោង ១១:៥៩ នាទីយប់ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ នេះតទៅ ដូចមានលក្ខណ្ឌខាងក្រោម៖

- អ្នកដំណើរមិនមានលទ្ធផលតេសវិជ្ជមានកូវីត-១៩ ក្នុងរយៈពេល ១៤ ថ្ងៃនៅមុនធ្វើដំណើរ និងមិនកំពុងរងចាំលទ្ធផលតេសកូវីត ក្នុងកំឡុងពេលកំពុងរងចាំការធ្វើដំណើរ
- អ្នកដំណើរត្រូវកក់សំបុត្រធ្វើដំណើរតាម "Green Zoon Flight"។ មានន័យថាពុំមានអ្នកដំណើរជាមួយដែលទើបមកពីប្រទេសផ្សេង(ក្រៅពីអូស្ត្រាលី)នៅលើយន្តហោះនោះ លើកលែងតែអ្នកធ្វើដំណើរដែលមកពីប្រទេសផ្សេងនោះបានស្នាក់នៅក្នុងប្រទេសអូស្ត្រាលី យ៉ាងហោចណាស់បាន១៤ ថ្ងៃហើយនៅមុនពេលចេញដំណើរ
- អ្នកដំណើរត្រូវផ្តល់ពត៌មានអំពីអាសយដ្ឋាន លេខទំនាក់ទំនងនៅក្នុងប្រទេសនូវែលហ្សេឡង់ និងបំពេញបែបបទពីសុខភាពរបស់ខ្លួនមុនពេលហោះហើរ
- ប្រសិនបើអ្នកដំណើរមានរោគសញ្ញាផ្តាសាយ ឬគ្រុនក្តៅ គឺមិនអនុញ្ញាតឱ្យធ្វើដំណើរបានទេ
- អ្នកដំណើរត្រូវពាក់ម៉ាស់នៅពេលហោះហើរ
- អ្នកដំណើរត្រូវប្រើប្រាស់កម្មវិធី NZ COVID Trace ក្នុងពេលស្នាក់នៅក្នុងប្រទេសនូវែលហ្សេឡង់
- អ្នកដំណើរបរទេសដែលធ្វើដំណើរពីប្រទេសអូស្ត្រាលីចូលប្រទេសនូវែលហ្សេឡង់ហើយត្រូវការជំនួយគាំទ្រផ្នែកកិច្ចការកុងស៊ុល ត្រូវទំនាក់ទំនងផ្ទាល់ជាមួយស្ថានទូត ឬកុងស៊ុលរបស់ខ្លួន។

សូមជម្រាបជូនផងដែរថា ការធ្វើដំណើរពីប្រទេសនូវែលហ្សេឡង់ ចូលមកប្រទេសអូស្ត្រាលីក៏តម្រូវបំពេញលក្ខខណ្ឌប្រហាក់ប្រហែលគ្នានេះដែរ និងសូមស្វែងយល់ពត៌មានលម្អិតបន្ថែមតាមគេហទំព័រ៖

1.) New Zealand to Australia: https://covid19.govt.nz/travel-and-the-border/ quarantine-free-travel/quarantine-free-travel-with-australia/travel-from-new-zealand-to-australia-quar antine-free-travel/

2.) Australia to New Zealand: https://covid19.govt.nz/travel-and-the-border/quarantine-free-travel/quarantine-free-travel-with-australia/travel-from-australia-to-new-zealand-quarantine-free-travel/

អាស្រ័យហេតុនេះ សូមបងប្អូនទាំងអស់មេត្តាជ្រាបជាពត៌មាន តាមការគួរ។

ថ្ងៃសុក្រ ១២ រោច ខែចេត្រ ឆ្នាំឆ្លូត ទោស័ក ព.ស. ២៥៦៤

កង់បេរ៉ា ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០២១

5 Canterbury Crescent Deakin ACT 2600, Tel: (02) 6273 5867 / 6273 8064, Fax: (02) 6273 1053
E-mail: Cambodianembassy@ozemail.com.au Website: www.embassyofcambodia.org.au